ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ១២៧២១/២៤ កសក.អល

ថ្ងៃ ច័ន្ទ ៤ កើត ខែ កត្ដិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ២០២៤

## ជម្រាបមក

## លោកប្រធានក្រុមហ៊ុន សុខ គង់ អាហារ័ណ នីហារ័ណ

**កម្មវត្ថុ ៖** ការសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាស្ដីពីការផ្គត់ផ្គង់ប្រេងឥន្ធនៈប្រើប្រាស់ប្រចាំឆមាសទី២ ឆ្នាំ២០២៤ របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**យោង ៖** កំណត់ហេតុបើកសំណើដេញថ្លៃចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៤ និងកំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤ របស់គណៈកម្មាធិការលទ្ធកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ដីពីការផ្គត់ផ្គង់ប្រេងឥន្ធនៈប្រើប្រាស់ប្រចាំឆមាសទី២ ឆ្នាំ២០២៤ របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូម លោកប្រធាន ជ្រាបថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (គណៈកម្មាធិការលទ្ធកម្ម) បានសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនរបស់លោក ដើម្បីធ្វើការផ្គត់ផ្គង់ប្រេងឥន្ធនៈប្រើប្រាស់ប្រចាំឆមាសទី២ ឆ្នាំ២០២៤ របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងតម្លៃទឹកប្រាក់សរុបចំនួន ៧៩១ ៧៨៣ ៧០០៖០០ (ប្រាំពីររយកៅសិបមួយលានប្រាំពីររយប៉ែតសិបបីពាន់ប្រាំពីររយរៀលគត់) ជាតម្លៃកិច្ចសន្យា។

អាស្រ័យហេតុនេះ សូម លោកប្រធាន ជ្រាបជាព័ត៌មានតាមការគួរ។

សូម លោកប្រធាន ទទួលនូវការរាប់អានពីខ្ញុំ។

ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អនុប្រធានទី១

**គីម សុន**

**ចម្លងជូន៖**

-ក្រុមហ៊ុន កម្ពុជា តេលា

-ក្រុមហ៊ុន ហ៊ុយ ស្រាង នីហារ័ណ អាហារ័ណ

"ដើម្បីជ្រាប"

-ឯកសារ កាលប្បវត្តិ